00364066

D130/9/2

**Declassified to Public**
**12 April 2013**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២៦)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18/08/2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fry

## សម្ងាត់

## សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តី ស្នើសុំពន្យារពេលវេលាកំណត់សម្រាប់ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការប្រើភស្តុតាង ដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 18/08/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fry

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE

**សហមេធាវីការពារក្តី**
ផាត់ ពៅសៀង
Diana ELLIS

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង**

អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "សំណើជាបន្ទាន់របស់មេធាវីការពារក្តីស្នើសុំពន្យារពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម" ដែលដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ("សំណើសុំ")។

១. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេច លើការប្រើភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ("ដីកាសម្រេច")[១]។ ដីកាសម្រេចនេះ ត្រូវបានជូនដំណឹងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩។

២. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទ បានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ។

៣. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តី បានដាក់សំណើស្នើសុំពន្យារពេលវេលាកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍។ ភាគីផ្សេងៗទៀត មិនបានដាក់ចម្លើយតបទៅនឹងសំណើសុំក្នុងពេលវេលាកំណត់ ដូចមានចែងនៅក្នុងមាត្រា៨.៣ នៃសេចក្តីណែនាំអនុវត្តលើការដាក់ឯកសារចំពោះមុខ អ.វ.ត.ក នោះទេ (វិសោធនកម្មលើកទី៤)។

៤. តាមរយៈសំណើសុំរបស់ខ្លួន សហមេធាវីការពារក្តីជនត្រូវចោទ ស្នើសុំពន្យារពេលដប់បួន(១៤)ថ្ងៃបន្ថែមទៀត ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច។

៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើសុំរបស់សហមេធាវីការពារក្តីធ្វើឡើងដោយផ្អែកលើមូលហេតុដូចខាងក្រោម៖ ១) បញ្ហាដែលត្រូវលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ គឺជាបញ្ហាស្មុគស្មាញ ដែលត្រូវការជំនួយពីសមាជិកទាំងអស់របស់ក្រុមមេធាវីការពារក្តី និង ២) សហមេធាវី

---

[១] ដីកាសម្រេចលើការប្រើភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, D130/8។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00364068



អន្តរជាតិ និងទីប្រឹក្សាផ្នែកច្បាប់មាន "ធុរៈផ្ទាល់ខ្លួនដែលបានគ្រោងទុកពីមុន" ដែលធ្វើឲ្យពួកគាត់ "ជួបការលំបាក" ក្នុងការដោះស្រាយបញ្ហានៅខែសីហានេះ។ សហមេធាវីការពារក្ដីបានលើកឡើងបន្ថែមថា ប្រសិនបើសំណើសុំនេះត្រូវបានសម្រេចអនុញ្ញាតឲ្យនោះ សហមេធាវីការពារក្ដីនឹងមិនជំទាស់ទៅនឹងសំណើស្រដៀងគ្នា ដែលស្នើសុំដោយភាគីផ្សេងៗ ឬសហព្រះរាជអាជ្ញា នៅក្នុងការដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍នេះទេ។

៦. អនុលោមតាមវិធាន៣៩(៤)(ក) នៃវិធានផ្ទៃក្នុង តាមរយៈពាក្យស្នើសុំរបស់ភាគីពាក់ព័ន្ធ អង្គបុរេជំនុំជម្រះ អាចពន្យារពេលវេលាកំណត់។

៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វាជាផលប្រយោជន៍របស់ជនត្រូវចោទ ក្នុងការមានអ្នកតំណាងផ្នែកច្បាប់តាមជម្រើសរបស់ខ្លួន។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា សំណើសុំត្រូវបានដាក់មុនហួសកំណត់នៃពេលវេលាកំណត់។

៨. អង្គបុរេជំនុំជម្រះយល់ស្របនឹងមូលហេតុដែលលើកឡើងនៅក្នុងសំណើសុំ និងកត់សម្គាល់នូវអង្គហេតុដែលថា សហព្រះរាជអាជ្ញា ឬមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី មិនបានជំទាស់នឹងសំណើសុំនេះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច÷**

**អនុញ្ញាត** ចំពោះសំណើសុំពន្យារពេលវេលាកំណត់សម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍។

**បន្ទាប់មក** សហមេធាវីការពារក្ដីជនត្រូវចោទ ត្រូវដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួន **ត្រឹមម៉ោង ១២ ថ្ងៃត្រង់ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩។**

ភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**